ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ៖ ០៣០ សជណ.សក.ដជ១

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការកំណត់ពេលវេលានៃការស្នើសុំលិខិតអនុញ្ញាតក្រុមហ៊ុនភ្នាក់ងារនាវា

យោងតាមប្រកាសលេខ១៨៩ ប្រក.សក.ដជ១. ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីនីតិវិធីផ្ដល់លិខិតអនុញ្ញាតក្រុមហ៊ុនភ្នាក់ងារនាវា ក្រសួងសាធារណការ និងដឹកជញ្ជូនសង្កេតឃើញថា ក្រោយពីប្រកាសស្ដីពីនីតិវិធីផ្ដល់លិខិតអនុញ្ញាតក្រុមហ៊ុនភ្នាក់ងារនាវាបានចូលជាធរមានរួចមក ក្រុមហ៊ុនភ្នាក់ងារនាវាមួយចំនួនពុំទាន់បានមកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ដើម្បីក្លាយជាក្រុមហ៊ុនភ្នាក់ងារនាវាស្របច្បាប់នៅឡើយ។

ក្នុងន័យនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមរំលឹកដល់ក្រុមហ៊ុនភ្នាក់ងារនាវាទាំងអស់ឱ្យមកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតភ្នាក់ងារនាវា ឱ្យបានត្រឹមថ្ងៃទី២៩ **ខែកក្កដា ឆ្នាំ២០២២** មុនពេលដែលប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ (Port EDI) ដាក់ឱ្យដំណើរការជាផ្លូវការ។ ក្នុងករណីក្រុមហ៊ុនភ្នាក់ងារនាវាដែលមិនបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនោះទេ ក្រុមហ៊ុននឹងពុំមានសិទ្ធិក្នុងការទទួលបានគណនីប្រើប្រាស់ក្នុងប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិកកំពង់ផែ (Port EDI) ដើម្បីប្រើប្រាស់សម្រាប់រៀបចំបែបបទនាវាចូល-ចេញកំពង់ផែឡើយ។

ក្រសួងសាធារណការ និងដឹកជញ្ជូន សង្ឃឹមយ៉ាងមុតមាំថា ក្រុមហ៊ុនភ្នាក់ងារនាវាទាំងអស់បានជ្រាបជាព័ត៌មាន និងអនុវត្តតាមសេចក្ដីជូនដំណឹងនេះ។

ថ្ងៃ...............ខែ...........ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០២២

ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៩០, (៨៥៥) ២៣ ៤២៧ ៨៦២